ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ.១៣៣៧៤អពដ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការទទួលយកប័ណ្ណសម្គាល់ការបង់ពន្ធមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ

អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយសសូមជម្រាបជូនម្ចាស់យានយន្តទាំងអស់មេត្តាជ្រាបថា អគ្គនាយកដ្ឋានពន្ធដារសង្កេតឃើញម្ចាស់យានយន្ត បានមកបំពេញកាតព្វកិច្ចដាក់លិខិតប្រកាសបង់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៥ ហើយមានម្ចាស់យានយន្តភាគច្រើនបានស្នើសុំធ្វើប័ណ្ណសម្គាល់ការបង់ពន្ធមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ។

អគ្គនាយកដ្ឋានពន្ធដារ បានធ្វើការបោះពុម្ពប័ណ្ណសម្គាល់ការបង់ពន្ធមធ្យាបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ និងបានប្រគល់ជូនទៅតាមសាខាពន្ធដារខេត្ត-ខណ្ឌ និងធនាគារដែលមានកិច្ចសហប្រតិបត្តិការជាមួយអគ្គនាយកដ្ឋានពន្ធដារ ។ កន្លងមក មានម្ចាស់យានយន្តមួយចំនួន បានមកទទួលយកប័ណ្ណសម្គាល់ការបង់ពន្ធនេះរួចរាល់ហើយ តែមានម្ចាស់យានយន្តមួយចំនួនទៀតមិនទាន់បានមកទទួលយកប័ណ្ណនៅឡើយ។

ដូច្នេះ ដើម្បីផ្តល់ភាពងាយស្រួលដល់ម្ចាស់យានយន្តក្នុងការបំពេញកាតព្វកិច្ចប្រកាសបង់ពន្ធសម្រាប់ឆ្នាំ២០១៦ និងឆ្នាំបន្តបន្ទាប់ អគ្គនាយកដ្ឋានពន្ធដារ សូមជូនដំណឹងដល់ម្ចាស់យានយន្តដែលបានស្នើសុំធ្វើប័ណ្ណសម្គាល់ការបង់ពន្ធមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ តែមិនទាន់ទទួលបាននៅឡើយ សូមអញ្ជើញមកទទួលយកប័ណ្ណសម្គាល់ការបង់ពន្ធនេះ នៅតាមទីតាំងដែលម្ចាស់យានយន្តបានស្នើសុំ ដោយយកមកជាមួយនូវបង្កាន់ដៃទទួលប្រាក់ពន្ធ ដែលបញ្ជាក់ការស្នើសុំធ្វើប័ណ្ណសម្គាល់ការបង់ពន្ធមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមនិងជឿជាក់យ៉ាងមុតមាំថា ម្ចាស់យានយន្តទាំងអស់ដែលបានស្នើសុំធ្វើប័ណ្ណសម្គាល់ការបង់ពន្ធមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ហើយមិនទាន់បានមកទទួលយក នឹងអញ្ជើញមកទទួលយកប័ណ្ណសម្គាល់ការបង់ពន្ធ សម្រាប់បំពេញកាតព្វកិច្ចពន្ធរបស់ខ្លួនក្នុងឆ្នាំ២០១៦ នេះ ឱ្យបានទាន់ពេលវេលា។

រាជធានីភ្នំពេញ ថ្ងៃទី១២ខែ សីហា ឆ្នាំ២០១៦

Collection by VCAT Professional Consultant

អគ្គនាយកដ្ឋានពន្ធដារ